00775950

E166

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អនុស្សរណៈ-អង្គជំនុំជម្រះសាលាដំបូង**

កាលបរិច្ឆេទៈ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២

**ជូនចំពោះ:** ភាគីនៃសំណុំរឿង ០០២

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង, មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង និងប្រធានអង្គភាពគាំពារសាក្សី និងអ្នកជំនាញ

**កម្មវត្ថុ:** **ការស្តាប់សក្ខីកម្មរបស់អ្នកជំនាញដែលមានរហស្សនាម TCE-38 និង TCE-44**

កាលពីថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ កន្លងទៅ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងទៅភាគីអំពីចេតនារបស់ខ្លួនក្នុងការស្តាប់សក្ខីកម្មរបស់អ្នកជំនាញរបស់អង្គជំនុំជម្រះ ដែលមានរហស្សនាម TCE-38 និង TCE-44 ក្នុងអំឡុងពេលនៃសវនាការលើសំណុំរឿង ០០២/១ (ឯកសារ E131/1 ឧបសម្ព័ន្ធ ខ សម្ងាត់)។ កាលពីថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១១ អង្គជំនុំជម្រះបានជូនដំណឹងថាកិច្ចខិតខំក្នុងការបញ្ជាក់អំពីការចូលរួមបានក្នុងសវសនការរបស់អ្នកជំនាញដែលមានរហស្សនាម TCE-38 និង TCE-44 កំពុងតែប្រព្រឹត្តិទៅ ហើយអង្គជំនុំជម្រះនឹងផ្តល់ព័ត៌មានបន្ថែមពាក់ព័ន្ធនឹងការកំណត់កាលបរិច្ឆេទនៃការស្តាប់សក្ខីកម្មអ្នកជំនាញទាំងនេះ ក្នុងពេលឆាប់ៗតាមដែលអាចធ្វើទៅបាន (ឯកសារ E155)។

ថ្វីបើអង្គភាពគាំពារសាក្សី និងអ្នកជំនាញបានខិតខំប្រឹងប្រែងយ៉ាងណាក៏ដោយ ក៏មកទល់នឹងពេលបច្ចុប្បន្ននេះ អង្គជំនុំជម្រះពុំទាន់មានលទ្ធភាពក្នុងការបញ្ជាក់អំពីការចូលរួមរបស់អ្នកជំនាញទាំងពីររូបខាងលើឡើយ។ ជាលទ្ធផល កាលពីពេលថ្មីៗ មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងទៅភាគីថាអង្គជំនុំជម្រះសាលាដំបូងនឹងពុំស្តាប់សក្ខីកម្មអ្នកជំនាញទាំងនេះក្នុងអំឡុងពេលសវនាការនាពេលបច្ចុប្បន្ននេះឡើយ។

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 06 / 02 / 2012
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

00775951

E166

ដោយអនុលោមតាមវិធាន ៩០ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសូមប្រគល់ភារកិច្ចក្នុងការសួរសំណួរទៅអ្នកជំនាញទាំងនេះ ទៅការិយាល័យសហព្រះរាជអាជ្ញា។ លើសពីនេះ អង្គជំនុំជម្រះសូមស្នើថាសហព្រះរាជអាជ្ញាត្រូវជូនដំណឹងមកអង្គជំនុំជម្រះ និងភាគីវិញក្នុងអំឡុងរយៈពេលបីសប្តាហ៍គិតចាប់ពីថ្ងៃនេះ ដោយភ្ជាប់មកជាមួយនូវអនុសាសន៍ស្តីពីការកំណត់ពេល និងនីតិវិធីនៃការស្តាប់សក្ខីកម្មរបស់អ្នកជំនាញទាំងពីររូបនេះ។ ហេតុដូច្នេះ អង្គជំនុំជម្រះអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាជួបទាក់ទងជាមួយអ្នកជំនាញទាំងពីររូបខាងលើ ក្នុងគោលបំណងនៃការបញ្ជាក់អំពីភាពអាចចូលរួមសវនាការរបស់ពួកគេ និងដើម្បីជួយដល់អង្គជំនុំជម្រះក្នុងការរៀបចំផែនការការងារ និងការកំណត់កាលបរិច្ឆេទនៃការស្តាប់សក្ខីកម្មរបស់អ្នកជំនាញទាំងពីររូប។ ដើម្បីជាសម្អាងក្នុងការចាត់តាំងភារកិច្ចនេះទៅសហព្រះរាជអាជ្ញា អង្គជំនុំជម្រះនឹងចេញដីកាកោះហៅអ្នកជំនាញទាំងពីររូបក្នុងពេលដ៏ឆាប់ខាងមុខ។ ដើម្បីធានាឱ្យមានតម្លាភាព និងការរៀបចំប្រកបដោយប្រសិទ្ធភាព អង្គជំនុំជម្រះសូមស្នើឱ្យសហព្រះរាជអាជ្ញាចម្លងជូនផ្នែកអង្គភាពគាំពារសាក្សី និងអ្នកជំនាញនូវសារអេឡិចត្រូនិកស្តីពីការប្រាស្រ័យទាក់ទងការងារទាំងអស់ជាមួយអ្នកជំនាញដែលមានរហស្សនាម TCE-38 និង TCE-44 ។

អង្គជំនុំជម្រះបានជ្រាបថាភាគីមួយចំនួន បានធ្វើការជំទាស់ទៅនឹងការស្តាប់សក្ខីកម្មរបស់អ្នកជំនាញទាំងពីរនេះ ក្នុងនាមជាអ្នកជំនាញ។ នៅដំណាក់កាលនេះ អង្គជំនុំជម្រះសូមធ្វើការបញ្ជាក់អំពីចេតនារបស់ខ្លួនក្នុងការស្តាប់សក្ខីកម្មរបស់ពួកគាត់នៅសវនាការតែប៉ុណ្ណោះ។ ចំណែកការសម្រេចជាស្ថាពរអំពីគុណវុឌ្ឍិរបស់ពួកគេ អង្គជំនុំជម្រះនឹងធ្វើនៅពេលសមស្របខាងមុខ។